# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:...០៣...សរណន**

# សារាចរណែនាំ

## ស្តីពី

## ការការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ការទប់ស្កាត់ និងការបង្ក្រាបល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ឆ្នាំ វក ឆស័ក ព.ស ២៥៤៨ ក្នុងថ្ងៃទី ១៣ ទី ១៤ និងទី ១៥ ខែ មេសា ឆ្នាំ ២០០៤

---

បន្ទាប់ពីការអនុវត្តនយោបាយ ឈ្នះ ឈ្នះ របស់រាជរដ្ឋាភិបាលមក ព្រះរាជាណាចក្រកម្ពុជា បានទទួលនូវសន្តិភាពពេញលេញទូទាំងប្រទេស ប្រជាពលរដ្ឋខ្មែរមានឱកាសធ្វើដំណើរទៅមក ដើម្បីធ្វើអាជីវកម្មនានា សួរសុខទុក្ខគ្រួសារ ជួបជុំញាតិមិត្ត ជាពិសេសការប្រារព្ធពិធីលេងល្បែង របាំប្រជាប្រិយ និងការរាំកំសាន្ត ស្របតាមទំនៀមទំលាប់ជាតិខ្មែរ យ៉ាងសប្បាយរីករាយក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិម្តងៗ ។

រាជរដ្ឋាភិបាលបានចេញសារាចរណែនាំលេខ ០៩ សរណន ចុះថ្ងៃ ទី ១៩ ខែ មិថុនា ឆ្នាំ ២០០៣ ដើម្បីប្រគល់ភារកិច្ចជូនក្រសួង ស្ថាប័ន និងខេត្ត-ក្រុង អនុវត្តជាអចិន្ត្រៃយ៍ ស្តីពីការរៀបចំចាត់តាំងព្រះរាជពិធីបុណ្យទ្វាទសមាស បុណ្យប្រពៃណីជាតិ ប្រពៃណីសាសនា បុណ្យជាតិ-បុណ្យអន្តរជាតិ រួចហើយ ។ ប៉ុន្តែនៅពេលកន្លងមកថ្មីៗនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញថា បាតុភាពលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ បានកកើតឡើងតាមមូលដ្ឋាន និងតំបន់មួយចំនួននៃខេត្ត-ក្រុង បណ្តាលអោយកើតមានជាបទល្មើសឧក្រិដ្ឋផ្សេងៗ គួរអោយកត់សំគាល់ ។

ដើម្បីថែរក្សា ការពារវប្បធម៌ ប្រពៃណីជាតិដ៏រុងរឿងពីបុរាណរបស់ខ្មែរ និងធានាការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ទប់ស្កាត់ និងបង្ក្រាបការលេងល្បែងស៊ីសងខុសច្បាប់គ្រប់

ប្រភេទនៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំ វក ឆស័ក ព.ស ២៥៤៨ ត្រូវនឹងថ្ងៃទី ១៣ ទី ១៤ និងទី ១៥ ខែ មេសា ឆ្នាំ ២០០៤ រាជរដ្ឋាភិបាល សូមធ្វើការណែនាំដូចតទៅ ÷

១-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងធម្មការ និងសាសនា ក្រសួងទេសចរណ៍ និង គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ត្រូវធ្វើការណែនាំដល់មន្ទីរ អង្គភាពជំនាញ ក្រោមឱវាទ របស់ខ្លួន និងប្រជាពលរដ្ឋទូទាំងប្រទេស អោយរៀបចំតុបតែងលំអលំនៅដ្ឋាន ទីក្រុង ទីប្រជុំជន ទីសាធារណៈ វត្តអារាម និងរមណីយដ្ឋាននានា ចាត់តាំងពិធីគោរពវិញ្ញាណក្ខន្ធរបស់បុព្វបុរស ជីដូនជីតា ញាតិសន្តាន ដែលបានធ្វើមរណកាលកន្លងទៅ ការលេងល្បែង របាំប្រជាប្រិយ និងការរាំកំសាន្ត ស្របតាម ប្រពៃណីជាតិខ្មែរពីបុរាណនៅតាមទីវត្តអារាម រមណីយដ្ឋាននានា និងតាមមូលដ្ឋានភូមិ ឃុំ និងសង្កាត់ របស់ខ្លួន អោយបានសប្បាយរីករាយ ។

២-ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គបញ្ជាការដ្ឋានកង យោធពលខេមរភូមិន្ទ និងកងរាជអាវុធហត្ថ ត្រូវធ្វើការណែនាំដល់គ្រប់ខេត្ត ក្រុង តាមជំនាញរៀងៗខ្លួន ដើម្បីមានវិធានការម៉ឺងម៉ាត់ ក្នុងកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ធានាទប់ស្កាត់ អំពើលួច ឆក់ ប្លន់ និងអំពើល្មើសច្បាប់ផ្សេងៗទៀត ជាពិសេសការទប់ស្កាត់ និងបង្ក្រាបរាល់ការលេងល្បែង ស៊ីសងខុសច្បាប់គ្រប់ប្រភេទ ដែលជាមូលហេតុចម្បងបង្កអោយ មានអំពើឧក្រិដ្ឋ និងបទល្មើសព្រហ្មទណ្ឌ នានា ក្នុងឱកាសដែលប្រជាពលរដ្ឋទូទាំងប្រទេស ប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ខាងមុខនេះ ។

ទទួលបានសារាចរណែនាំនេះ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ក្រសួងធម្មការ និងសាសនា ក្រសួងទេសចរណ៍ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គបញ្ជាការដ្ឋាន កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ និង អភិបាលគ្រប់ខេត្ត ក្រុង ត្រូវធ្វើការផ្សព្វផ្សាយ និងធ្វើការណែនាំលំអិតបន្ថែមទៀត ដើម្បីអនុវត្តតាម ខ្លឹមសារខាងលើ ដល់កំលាំងមានសមត្ថកិច្ច និងមន្ត្រីក្រោមឱវាទ អោយទទួលអនុវត្តប្រកបដោយ ប្រសិទ្ធភាព ។

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- សាលាខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន